# ក្បួនរាជសព្ទ



# បរិយាយសេចក្ដី

ក្បួនរាជសព្ទនេះ កាលព្រះពុទ្ធសករាជកន្លងបាន ២៣៩៩ (គ.ស 1855) ព្រះបាទសម្ដេចព្រះហរិរក្សរាមា ព្រះចៅក្រុងកម្ពុជាធិបតី ជាអម្ចាស់ជីវិតលើត្បូងទ្រង់ត្រាស់ឲ្យប្រជុំព្រះថេរានុត្ថេរៈ និងមន្ត្រី ដែលចេះដឹង ដូចនាមបកប្រែពាក្យរាជសព្ទបុរាណដែលមានវិបត្តិមករើធ្វើជាថ្មី ដើម្បីទុកឲ្យរាជបរិស័ទហាត់រៀនរាល់គ្នា ពួកខ្ញុំរាជការជាច្រើនក្នុងគ្រាជាន់នោះសឹងចាំស្ទាត់ទាំងបុរសស្ត្រី។ លុះមកដល់ពុទ្ធសករាជ ២៤៧៣ (គ.ស 1929) អញខ្ញុំបានផ្ញើក្បួនរាជសព្ទដែលធ្វើកាលគ្រាជាន់នោះ ទៅ ឲ្យអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពផ្សាយទៀតតែឥតមានកែប្រែអ្វីបន្តិចទេ ដើម្បីទុកឲ្យជនានុជនដែលមានឱកាសទំនេរ ទៅសន្និបាតមើលរឿងផ្សេងៗដែលមានក្នុងព្រះរាជបណ្ណាល័យ ជាគតិឲ្យរុងរឿងសតិបញ្ញាជាគ្រាទី២។

ឥឡូវនេះ អញខ្ញុំដឹងថា សៀវភៅរាជសព្ទក្នុងទីព្រះរាជបណ្ណាល័យ បានចំណាយអស់ជាច្រើននៅសល់តិចណាស់ គួរតែរកឱកាសបោះពុម្ពផ្សាយទៀតជាថ្មី តែគួរធ្វើសង្ខេបបែបខ្លី ដ្បិតសេចក្ដីក្នុងរាជសព្ទជាន់នោះពិស្ដារពេក ជនដែលចង់ចេះពុំអាចចាំបានដោយងាយ។

នោះយើងបានប្រជុំលោកអ្នកចេះទាំងឡាយមកជួយធ្វើ ដូចមាននាមមកនេះ

ព្រះថេរៈ គឺ

ព្រះមហាព្រហ្មមុនី **នាម អ៊ូ**

ព្រះភិក្ខុ ធម្មសិរិ **នាម សុវណ្ណ**

ពួកឧបាសក គឺ

ព្រះវររាជវោហារ **នាម កែវ** ក្រុមរាជបណ្ឌិត្យ

អាចារ្យ ម៉ូត រាជលេខានុការ ក្នុងសម្ដេចព្រះរាជអយ្យកា។

មហា ទិន ហួត ក្រុមពុទ្ធសាសនបណ្ឌិត្យ មកជួយរើសសព្ទណា គួរប្រើឲ្យសមបែបខ្លីម្ដងទៀតជាគ្រាទី៣។

ក៏ឯពាក្យដែលហៅថារាជសព្ទនោះ ពុំចំពោះតែយកមគធភាសា និងសំស្ក្រឹតភាសាមកប្រើទេ សូម្បីខេមរភាសា លោកបុរាណាចារ្យក៏មានយកមកប្រើដែរ ក៏ប៉ុន្តែមកសន្មតហៅឲ្យខុសនឹងពាក្យប្រើធម្មតា ដូចពាក្យថា **ផ្ទំ** និង **ស្រង់** ជាដើម។

ឯរាជសព្ទដែលបោះពុម្ពក្នុងព្រះពុទ្ធសករាជ ២៤៨៥ (គ.ស 1941) នេះពុំបានផ្លាស់ផ្លែងសព្ទដើម ឬបញ្ញត្តថែមសព្ទថ្មីទៀតទេ គ្រាន់តែកែអក្សរឲ្យត្រឹមត្រូវ និងរៀបពាក្យ

ឲ្យរៀងតាមលំដាប់អក្សរ តាមសំដីដែលប្រើធម្មតា ដើម្បីឲ្យងាយរករាជសព្ទដែលត្រូវការ។

ពាក្យជារាជសព្ទនោះ បើ នឹងបញ្ញត្តឲ្យគ្រប់សម្ដីដែលត្រូវការនិយាយទាំងអស់ ក៏នឹងក្លាយទៅជាភាសាមួយដោយឡែក នាំឲ្យចេះមិនចប់ នឹងនាំឲ្យពួកលោកអ្នកមិនប៉ិនប្រសប់រាជសព្ទ ធុញទ្រាន់ ខ្លាចមិនហ៊ានចូលមកកាន់ព្រះរាជសំណាក់ផង។

ជាទំនៀមរបស់ភាសាគ្រប់ជាតិ តែងមានបញ្ញត្តសព្ទខ្លះជាពិសេស សម្រាប់និយាយគោរពដល់ក្សត្រខត្តិយត្រកូល ឬលោកអ្នកមានសក្ដានុពលធំជាងជាដរាប។

កាលបើពាក្យជារាជសព្ទ ឬពាក្យខ្ពស់សម្រាប់ជាតិត្រូវតែនិយាយខានមិនបានដូច្នេះហើយ បានជាអញខ្ញុំព្យាយាមរៀបចំក្បួនរាជសព្ទនេះ ទុកជាសម្បត្តិជួយឲ្យងាយដល់អ្នកត្រូវការ។

ក្នុងក្បួនរាជសព្ទនេះ បានកាត់ចោលពាក្យណាដែលមិនសូវត្រូវការប្រើញឹកញយបន្ថយឲ្យតិចចុះ ដើម្បីឲ្យងាយសិក្សា ប្រសិនបើពាក្យណាមួយជាខេមរភាសាក្ដី ភាសាអ្នកបរទេសក្ដី ដែលគ្មានបញ្ញត្តិក្នុងក្បួនរាជសព្ទនេះទេ ត្រូវនិយាយតាមសម្ដីដែលធ្លាប់និយាយដដែល តែត្រូវថែមពាក្យថា **ទ្រង់** ឬ **ព្រះ** នាំមុខពាក្យ ដូចកិរិយាសព្ទថា **ឈ្ងោក**, **ងាក** ថា **ទ្រង់ឈ្ងោក**, **ទ្រង់ងាក** ឬពាក្យជានាមសព្ទ ថា **រូប**, **អង្គ** ថា **ព្រះរូប** ឬ**ព្រះបរមរូប**, **ព្រះអង្គ** ជាដើម តាមសមគួរដល់ពាក្យដែលគួរថែម។

មានពាក្យខ្លះដូច **នាឡិកា**, **សៀវភៅ**, **ផើងផ្កា** នឹងប្រើពាក្យ **ព្រះ** នាំមុខមិនពីរោះ ត្រូវប្រើពាក្យ **ព្រះរាជទ្រព្យ** ភ្ជាប់ខាងក្រោយថា **នាឡិកាព្រះរាជទ្រព្យ** បើជាត្រីសាច់បន្លែ ត្រូវភ្ជាប់ពាក្យថា **ព្រះស្ងោយ** ដូច **បន្លែព្រះស្ងោយ**... វិញ ចំណែកឈ្មោះរោគផ្សេងៗ ខ្លះនឹងប្រើពាក្យ **ព្រះ** ឬ **ព្រះរាជទ្រព្យ** ក៏មិនសម គួរនិយាយថា **ប្រឈួនព្រះរោគ**..... វិញ។

ន័យមួយទៀត តាមទំនៀមរាជសព្ទ បើពាក្យណាជានាមសព្ទ ច្រើនប្រើពាក្យ **ព្រះ** នាំមុខ ពាក្យណាជាកិរិយាសព្ទ ច្រើនប្រើពាក្យ **ទ្រង់** នាំមុខ តែគង់លើកទុកពាក្យខ្លះ ដូចពាក្យថា **ស្វេតច្ឆត្រ**... មិនមានពាក្យ **ព្រះ** នាំមុខពាក្យថា **ស្រង់** មិនមានពាក្យ **ទ្រង់** នាំមុខក៏បាន។ នាមសព្ទរួមចូលគ្នាពីរម៉ាត់ដូច **កព្រះហស្ត**, **ស្នាប់ព្រះសិរ** ជាដើម មិនប្រើពាក្យ **ព្រះ** ពីរដងថា **ព្រះកព្រះហស្ត**, **ព្រះស្នាប់ព្រះសិរ** ក៏មាន **ព្រះកនិដ្ឋាព្រះឱស្ឋ** នៅប្រើពាក្យ **ព្រះ** ទាំងពីរក៏មាន។

នាមសព្ទណា ប្រើជាកិរិយាសព្ទត្រូវថែមពាក្យថា **ទ្រង់** ដូចពាក្យថា **ទ្រង់ព្រះនិទ្រា** តែពាក្យខ្លះដូចជា **ទ្រង់ក្រោធ**, **ទ្រង់ប្រហារ**... មិនបានមានពាក្យ **ព្រះ** ទេ ដោយហេតុមិនស្រួលស្ដាប់មិនពីរោះត្រចៀក អ្នកត្រូវការគួរសង្កេតនិងលៃលក ប្រើឲ្យសមគួរតាមសេចក្ដីនោះៗ ដូចបានអធិប្បាយពន្យល់មកខាងលើនោះចុះ។

*វរចក្ររណរិទ្ធិ*

# វាចាអ្នកវាយអក្សរសាឡើងវិញ ធ្វើជាសៀវភៅអេឡិចត្រូនិក (E-book)

សៀវភៅ ក្បួនរាជសព្ទ ដែលមានចំណងជើងពីដើមថា ក្បួនរាជស័ព្ទ បានរៀបរៀងដាក់ឲ្យប្រើតាំងពីឆ្នាំ 1855 រហូតមកដល់ឆ្នាំ 1929 ទើបយកទៅបោះពុម្ពដោយមានសេចក្តីវែង ដោយសារប្រើអស់ទើបមកដល់ឆ្នាំ 1941 ក៏ចាប់បោះពុម្ពម្តងទៀតដោយសង្ខេបយកតែពាក្យសំខាន់ៗ និងតម្រៀបតាមព្យញ្ជនៈដើម្បីងាយស្រួលចាំ។

ខ្ញុំអាចសន្មតបានថាសៀវភៅក្បួនរាជសព្ទនេះ គឺបោះពុម្ពនៅឆ្នាំ 1941 ដោយរៀបពុម្ពអក្សរ ព្រោះមិនទាន់មានកុំព្យូទ័រទេ។ សៀវភៅនេះប្រហែលជាបោះពុម្ព ដោយមិនផ្អែកលើ វចនានុក្រមសម្តេច ជួន ណាត ទេ មើលទៅ ព្រោះមានពាក្យខ្លះសរសេរខុសពីវចនានុក្រម ដូច្នេះខ្ញុំក៏កែពាក្យខ្លះដែលខ្ញុំដឹងថាខុស មកតាមវចនានុក្រមជួនណាត វិញ គួរពុំគួរសូមអធ្យាស្រ័យ។

សៀវភៅ ក្បួនរាជសព្ទ ដែលខ្ញុំវាយអក្សរឡើងវិញធ្វើជាសៀវភៅអេឡិចត្រូនិកនេះ គឺសម្រាប់អាននិងស្វែងយល់ មិនសម្រាប់យកទៅបោះពុម្ពទេ ព្រោះ **មិនជាផ្លូវការ** គ្មានអ្នកត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ដូច្នេះខ្ញុំមិនទទួលខុសត្រូវនូវរាល់ពាក្យដែលបានសរសេរខុសដោយអចេតនាឡើយ។

---

ភ្នំពេញ, ថ្ងៃទី 27 ខែមករា ឆ្នាំ 2013
**អាក្បាលធំ**

**◎ ព័ត៌មានសៀវភៅ ៖**

- ឈ្មោះសៀវភៅ : ក្បួនរាជសព្ទ (1941)
- ចេញផ្សាយដោយ : ពុទ្ធសាសនបណ្ឌិត្យ
- ធ្វើជា E-book ដោយ : អាក្បាលធំ (2013)
- ទីតាំងទាញយក : ប្លកអាក្បាលធំ (www.akbalthom.blogspot.com)

# ១ ក

| | |
|---|---|
| ក | ព្រះសុរង |
| កជើង | ព្រះនិពន្ធបាទ, កព្រះបាទ |
| កដៃ | ព្រះករ, កព្រះហស្ត |
| កង | ព្រះវល័យ |
| កងកន់ | ព្រះពាហុរ័ក្ស, ព្រះពាហុរ័តន៍ (ព្រះពាហុរត្ន) |
| កង្វេរ | ព្រះអង្គុសា |
| កញ្ចក់ឆ្លុះ | ព្រះឆាយ |
| កញ្ច្រឹល | ព្រះទទ្ម |
| កន្ទើយព្រងើយ | ទ្រង់ព្រះឧបេក្ខា |
| កន្ត្រៃ | ព្រះទម្រង់សុកន្ត |
| កន្ធោរតូច | ព្រះសុពណ្ណស្រី |
| កន្ធោរធំ | ព្រះសុពណ្ណរាជ |
| កន្ទក់លាងដៃ | ព្រះកុណ្ឌកី |
| កន្ទួតអូង | ព្រះគីវង្គ |
| កន្លើត | ព្រះតាលុ |
| កន្សែងទ្រាប់ថ្វាយបង្គំ | ព្រះកនិដ្ឋាបង្គំ |
| កន្សែងជូតខ្លួន | ព្រះកនិដ្ឋាព្រះអង្គ |
| កន្សែងជូតដៃ | ព្រះកនិដ្ឋាព្រះហស្ត |
| កន្សែងជូតមាត់ | ព្រះកនិដ្ឋាព្រះឱស្ឋ |
| កន្សែងជូតមុខ | ព្រះកនិដ្ឋាព្រះភក្ត្រ |
| កន្សែងជួតក្បាល | ស្ពាប់ព្រះសិរ |
| កម្រាល, កន្ទេល, ចៀមចំ, ព្រំ | ព្រះនិសជ្ជនីយ៍ |
| កាត់សក់ | ចម្រើនព្រះកេសា |
| កាល់ចិញ្ចើម | វិចិត្រព្រះភ្រូមោ |
| ការពាក់ត្រចៀក | ព្រះកុណ្ឌល |
| កុណ្ឌីទឹក | ព្រះសុវណ្ណភិង្គារ |
| កូនប្រសាប្រុស | ព្រះជីតុបតី |
| កូនប្រសាស្រី | ព្រះសុណិសា |
| កូបដំរី | ព្រះនាគាសនៈ |
| កើតទុក្ខ | ទ្រង់សោយទុក្ខ |

| | |
|---|---|
| កោរសក់ | ដាក់ព្រះកេសា |
| កៅអី | ព្រះសុវណ្ណកោច្ឆ: |
| កាំបិតកោរ | ព្រះទម្រង់ខុរ: |
| កាំបិតបត់ | ព្រះទម្រង់បិប្ផលី |
| កាំបិតបន្ទោះ | ព្រះទម្រង់ដងវែង (ដងង) |
| កាំបិតព្រា | ព្រះទម្រង់វាសី |
| កាំបិតស្នៀត ឬក្រឹស | ព្រះទម្រង់ឆុរិកា |
| កាំបិតស្លា | ព្រះទម្រង់បូគ: |
| កំភួនជើង | កំភួនព្រះបាទ |
| កំភួនដៃ | កំភួនព្រះហស្ត |
| កម្លាំងកាយ | ព្រះកាយពល |
| កំហាក | ព្រះខេឡាសុចិ |
| កម្អួត | ព្រះអាចៀន, ព្រះវមក: |
| កាំភ្លើង | ព្រះទម្រង់អគ្គី |
| ក្ដាញ់ | ទ្រង់បដិយ: |
| ក្បាល | ព្រះសិរ |
| ក្បាលជង្គង់ | ព្រះជានុ |
| ក្មួយប្រុស | ព្រះភាគិនេយ្យ |
| ក្មួយស្រី | ព្រះភាគិនេយ្យា |
| ក្រចក | ព្រះនខា |

-ក្រដាសប្រោះទឹកមាសបិទភ្ជាប់នឹងព្រៃ ឬក្រដាសបារាំងសរសេរតាំងតំណែងយសមន្ត្រីទាំងពួង តាំងពីឧកញ៉ាដរាបដល់ឃុន ម៉ឺន = សញ្ញាប័ត្រ។
-ក្រដាសសេនាបតីធ្វើតាំងតំណែងយស ឲ្យក្រមការ = ត្រាតាំង។
-ក្រដាសសរសេរតាំងតំណែងយសព្រះភិក្ខុសង្ឃទាំងពួង = សមណប័ត្រ។

| | |
|---|---|
| ក្រមាបង់ក | ព្រះសុភាក់ |
| ក្រពះ | ព្រះបិហក: |
| ក្រមួនមាត់ | នួនព្រះឱស្ឋ |
| ក្រយៅ | ព្រះបទរាជី |
| ក្រលៀន | ព្រះអនុជង្គ |
| ក្រឡេកមើល | ទ្រង់ឆ្មៀងព្រះនេត្រ |
| ក្រាស | ព្រះសម្អាងកេសី |
| ក្រោកពីដេក | ទ្រង់តើន, ទ្រង់បពុជ្ឈនាការ |

| | |
|---|---|
| ក្លស់ | ព្រះក្លស់ |
| ក្លាហាន | ព្រះវិសារទៈ |
| ក្លៀក | ព្រះកច្ឆៈ |
| ក្អក | ព្រះកាសៈ |
| ក្អមពួច | ព្រះសុវណ្ណកុម្ភៈ |
| ក្អួត | ទ្រង់អាចៀន |
| ក្អែល | ព្រះរជ្ជោជល |

---

## ខ ខ ខ

| | |
|---|---|
| ខាក | ទ្រង់កក្ខារី |
| ខឹងច្រើន | ទ្រង់ក្រោធ, ទ្រង់ពិរោធ |
| ខឹងតិច | ទ្រង់ខ្វាល់ |
| ខឹមខាត់ } ខ្សែក្រវាត់ | ព្រះកាយពន្ធន៍ |
| ខួរក្បាល | ព្រះមត្ថលុង្គ |
| ខោជើងវែង | ស្នាប់ព្រះជង្ឃ |
| ខោស្នាប់ភ្លៅ | ស្នាប់ព្រះឱរូ (ឱរុ) |
| ខ្ទិល | ទ្រង់កោសជ្ជៈ |
| ខ្នង | ព្រះប្រឹស្ដាង្គ |
| ខ្នើយ | រងព្រះបាទ |
| ខ្នើយផ្អែក | ព្រះខ្នល់ |
| ខ្នើយរងស្មង | រងព្រះជង្ឃ |
| ខ្នើយឱប | នែបព្រះអង្គ |
| ខ្មៀរអាចម៍ | ព្រះខ្នាច់ |
| ខ្ពុរមាត់ | ទ្រង់វិក្ខាលនៈ |
| ខ្មាសរបស់ប្រុស | ព្រះសិដ្ឋលិង្គ |
| ខ្មាសរបស់ស្ត្រី | ព្រះយោនី |
| ខ្មៅដុស | ព្រះមសិ |
| ខ្យល់ចាប់ | ព្រះវាយុរោគ |
| ខ្លាច | ទ្រង់ព្រះភិរុកា |
| ខ្លាញ់ខាប់ | ព្រះមេទោ |

| | |
|---|---|
| ខ្លាញ់រាវ | ព្រះវសា |
| ខ្លួន | ព្រះកាយ |
| ខ្សៀ | ព្រះទំរង់ធុមវដ្ដី |

---

## ១ គ ๛

| | |
|---|---|
| គក់ (វាយ) | ទ្រង់ប្រហារ |
| គិត | ទ្រង់ព្រះចិន្ដា |
| គជ, តេជ, នប់, កុយ, គាថា | ព្រះគ្រូ |
| គូរ | ទ្រង់ព្រះលេខា |
| គោ | ព្រះទីន័ងឧសភរាជ |
| គោម | ព្រះឃរបទីប |
| គុំកួន | ទ្រង់អាឃាដ |
| គុម្ពត្រចៀក | ព្រះកាណ៌ |
| គ្រឿងក្រអូបសម្រាប់លាប | ព្រះសុគន្ធវិលេបនៈ |
| គំហក | ទ្រង់តជ្ជនាការ |
| គ្រហែម | ទ្រង់ព្រះឧក្កាសិត |
| គ្រុន | ព្រះទាហរោគ, ឌាហរោគ |
| គ្រូ | រាជគ្រូ |
| គ្រែ | ព្រះមញ្ចៈ |
| គ្រែដេក | ព្រះទែនបន្ទំ |
| គ្រែយាន | ព្រះរាជយានទុម៉ាត |
| គ្រែយានមាស | ព្រះសុវណ្ណរាជយាន |
| គ្រែអង្គុយ | ក្រឡាព្រះគំនាល់ |

---

## ១ ឃ ๛

| | |
|---|---|
| ឃើញ | ទ្រង់ទស្សនាការ |
| ឃ្លង់ | ព្រះកុដ្ឋរោគ |
| ឃ្លាន | ទ្រង់ជិឃច្ឆា |

---

## ◎ ង

| | |
|---|---|
| ងងុយ | ទ្រង់ព្រះថីនៈ |
| ងូតទឹក | ស្រង់ព្រះវារី |
| ងោកងុយ | ទ្រង់ព្រះមិទ្ធៈ |

---

## ◎ ច

| | |
|---|---|
| ចង្កា | ព្រះហនុកា |
| ចង្កើះ | ព្រះយមកា |
| ចង្កៀង | ព្រះតេលបទីប |
| ចង្កៀលក្រចក | ព្រះទម្រង់សុពណ្ណនខា |
| ចង្កួយស្មា | ព្រះអង្សកូដ |
| ចង្កៀលត្រចៀក | ព្រះទម្រង់សុវណ្ណកាណ៌ |
| ចង្កេះ | ព្រះអង្គៈ, ព្រះកដី |
| ចន្ទាស | ព្រះសណ្ឋាស |
| ចង្កុលម្រាមដៃ | ព្រះតជ្ជនាបាទ |
| ចារុ៌ចងដៃ | កែមព្រះករ |
| ចិញ្ចើម | ព្រះភូមោ, ព្រះភមុកា |
| ចិញ្ចៀន | ព្រះទម្រង់ |
| ចិត្ត | ព្រះហឫទ័យ |
| ចិត្តជា (បាត់ខឹង) | ទ្រង់ក្សាន្តព្រះហឫទ័យ |
| ចូលចិត្ត | ទ្រង់សន្និដ្ឋាន |
| ចែងថ្ងៃ | ព្រះខុទ្ទកបិឡកា |
| ចៅស្រី-ប្រុស | ព្រះរាជនត្តា |
| ចំណីបង្អែម | ព្រះឱជា |
| ចំឡក | ព្រះបស្សការ |
| ប្រចាប់ | សម្ពាហណៈ |
| ប្រមុះ | ព្រះនាសា |
| ប្រួចទឹក | ទ្រង់ទក្សិណោទក |
| ច្រៀង | ទ្រង់គីតាភិរម្យ |

---

## ◎ ឆ

| | |
|---|---|
| ឆត្រ | ព្រះក្លស់ |
| ឆ្លាក់ | ទ្រង់រចនា |
| ឆ្អឹង | ព្រះអដ្ឋិ |
| ឆ្អឹងជងកាំបិត | ព្រះអក្ខកា |

---

## ◎ ជ

| | |
|---|---|
| ជក់ | ទ្រង់សោយ |
| ជញ្ជឹង | ទ្រង់ព្រះវិចារណ៍ |
| ជន្លួញ | ព្រះបដោទ |
| ជាន់ | ទ្រង់អក្កមៈ |
| ជណ្ដើរ | ព្រះអឌ្ឍចន្ទ |
| ជីដូន | ព្រះអយ្យិកា |
| ជីដូនទួត | ព្រះអយ្យិកាទួត |
| ជីតា | ព្រះអយ្យកោ |
| ជីតាទួត | ព្រះអយ្យកោទួត |
| ជិនឆ្អន់ | ទ្រង់និព្វិទា |
| ជុក | ព្រះមោលី |
| ជុះអាចម៍ | ទ្រង់ចូលព្រះបង្គន់ធំ |
| ជម្រះធ្មេញ | ទ្រង់សោយព្រះស្ងួន្ត |

---

## ◎ ឈ

| | |
|---|---|
| ឈរ | ទ្រង់ស្ថិត |
| ឈមមុខត្រង់ | ទ្រង់ឆ្ពោះព្រះភក្ត្រ |
| ឈានជើង | ស្ដេចឈានព្រះបាទ |
| ឈាម | ព្រះលោហិត |
| ឈឺ | ប្រឈួន, ទ្រង់ព្រះអាពាធ, ទ្រង់ព្រះអផាសុក |
| ឈើខ្នាត | ព្រះរាជមានៈ |
| ឈើខ្នោសអណ្ដាត | ព្រះជិវ្ហាវិសោធន៍ |

| | |
|---|---|
| ឈើចាក់ធ្មេញ | ផ្ចាក់ព្រះទន្ត, ព្រះទន្តកដ្ឋ |
| ឈើច្រត់ | ព្រះទណ្ឌ: |
| ឈ្នួត | ព្រះវេដ្ឋន: |
| ឈ្លើ | ទ្រង់បរិមទ្ទ: |

## ០ ញ ០

| | |
|---|---|
| ញញឹម | ទ្រង់ព្រះសិតាការ: |
| ញើស | ព្រះសេទោ |

## ០ ដ ០

| | |
|---|---|
| ដន្លាប់ | ព្រះភ្នក់ |
| ដបកែវ | ព្រះករណ្ឌក: |
| ដបតែ | ព្រះបានកោស: |
| ដាវ | ព្រះទម្រង់អសិ |
| ដាវវែង | ព្រះទម្រង់អសិដងវែង |
| ដីខ្មៅសរសេរ | ព្រះកាឡមត្តិកា |
| ដីស | ព្រះបុស្សមត្តិកា |
| ដឹង | ទ្រង់ជ្រាប |
| ដើមទ្រូង | ព្រះឧរា |
| ដើរ | ទ្រង់យាងព្រះបាទ |
| ដើរដំណើរ | ទ្រង់ព្រះរាជដំណើរ |
| ដេក | ទ្រង់ផ្ទំ |
| ដេកលក់ | ទ្រង់ផ្ទំស្កល់ |
| ដៃ | ព្រះហស្ត |
| ដំបង | ព្រះទម្រង់គទាវុធ |
| ដំរីសម្រាប់គង់ | ព្រះទីន័ងគជេន្ទ្រ |
| ដោះ | ព្រះថ័ន |

## ១ ត ចប់

| | |
|---|---|
| តម | ទ្រង់ព្រហ្មចេត |
| តោក | ព្រះសុដ្ឋិការ |
| តាំង | ព្រះបីថំ |
| តែងរឿង-កាព្យ | ទ្រង់និពន្ធ |
| ត្បាល់បុកស្លា | ព្រះសុវណ្ណទន្ត, ស្នងព្រះទន្ត |
| ត្រកូល | រាជត្រកូល, ខត្តិយត្រកូល |
| ត្រចៀក | ព្រះស្រោត |
| ត្រា | ព្រះរាជវលញ្ឆករ |
| ត្រិះរិះ | ទ្រង់ព្រះតំរិះ |

---

## ១ ថ ចប់

| | |
|---|---|
| ថើប | ទ្រង់ចុម្ពិត |
| ថ្ងាស | ព្រះនលាត |
| ថ្ងូរ | ទ្រង់អដ្ដសរៈ |
| ថ្នាំរក្សារោគ | ព្រះឱសថ |
| ថ្គាល់ | ព្រះគណ្ឌៈ |
| ថ្លើម | ព្រះយកនៈ |

---

## ១ ទ ចប់

| | |
|---|---|
| ទាច | ព្រះវក្កៈ |
| ទិកោទឹក | ព្រះបានភិង្គារ |
| ទឹកកាម | ព្រះអសុចិ |
| ទឹកដោះ | ព្រះក្សីរ |
| ទឹកតែ | ព្រះបានរស |
| ទឹកត្រជាក់ | ព្រះសីតរស |
| ទឹកនោម | ព្រះមូត្រ |
| ទឹកភ្នែក | ព្រះអស្សុ |
| ទឹកមាត់ | ព្រះខេឡៈ |

| | |
|---|---|
| ទឹករំអិល | ព្រះលសិកា |
| ទឹកលាងអាចម៍ | ព្រះធារាបង្គន់ |
| ទឹកអប់ | ព្រះសុគន្ធ |
| ទឹកអប់សម្រាប់ងូត | ព្រះសុគន្ធវារី |
| ទូ | ព្រះកុញ្ចិកកោសៈ |
| ទូកគង់ | ព្រះទីន័ងនាវា |
| ទួញ | ទ្រង់សោក |
| ទៀន | ព្រះសិខាទីប |
| ទៅលេង | ស្ដេចប្រពាត |
| ទ្រគាក | ព្រះសុសោណី |
| ទ្រហោយំ | ទ្រង់ពិលាប |
| ទ្វារផុះ | ព្រះវច្ចមគ្គ |
| ទ្វារនោម | ព្រះបស្សាវមគ្គ |

---

## ៙ ធ ៚

| | |
|---|---|
| ធ្នូ | ព្រះទម្រង់កៅទណ្ឌ |
| ធាត់ | ព្រះថូលោ, មានព្រះអង្គ |
| ធូប | ព្រះធូប |
| ធ្មេញ | ព្រះទន្ត |

---

## ៙ ន ៚

| | |
|---|---|
| និយាយ | ទ្រង់មានព្រះបន្ទូល, ទ្រង់មានព្រះតម្រាស់, ព្រះសវនីយ (ព្រះអគ្គមហេសី) |
| និយាយការ | ទ្រង់មានព្រះរាជឱង្ការ |
| និយាយចំពោះ } | |
| ផ្ដើមឡើង } | ទ្រង់ប្រារព្ធ |
| និយាយបន្លឺឲ្យដឹង } | |
| ផ្សាយទូទៅ | ព្រះបន្ទូលសុរសីហនាទ |
| នោម | ទ្រង់ចូលព្រះបង្គន់តូច, ទ្រង់បន្ទោបស្សាវៈ |
| នៅ | គង់ |

| | |
|---|---|
| នៅផ្ទះ | គង់ព្រះដំណាក់ |

---

## ១ ប

| | |
|---|---|
| បបោសអង្អែល | ទ្រង់បរាមាស |
| បង | ព្រះរាម, ព្រះជេដ្ឋា |
| បង្គាប់ | ទ្រង់បញ្ជា |
| បង្អួចមានគន្លឹះ | ព្រះសីហបញ្ជរ |
| បង្អួចបើកទល់ | ព្រះកវាតា |
| បន្ទាត់ | ព្រះតន្តិ (ព្រះតន្តី) |
| បារី | ព្រះធុមវដ្ដី<br>ព្រះស្រីស្នួង |
| បាយ | ព្រះក្រយាស្ងោយ |
| បេះដូង | ព្រះហទយ: |
| ប្ដី | ព្រះស្វាមី, ព្រះភស្ដា |
| ប្រជុំចិញ្ចើម | ព្រះឧណ្ណាលោម |
| ប្រពន្ធ | ព្រះមហេសី, ព្រះជាយា |
| ប្រមាត់ | ព្រះបិត្ត: |
| ប្រជ្រុយ | ព្រះតិលកា |
| ប្រឡែង (ប្រលែង) ឬលេង | ទ្រង់ក្រសាល |
| ប្រាប់ | ទ្រង់ត្រាស់ |
| ប្រេង | ព្រះតេល: |
| ប្អូន | ព្រះអនុជ |

---

## ១ ផ

-ផែនប្រាក់ចារិកអក្សរតាំងតំណែងយសសេនាបតីនូវព្រះភិក្ខុរាជាគណ:ធំ = ហិរញ្ញបត្រ។
-ផែនមាសចារិកអក្សរទាំងព្រះនាមម្ចាស់ផែនដីនូវក្សត្រិយ៍ទាំងពួង និងព្រះសង្ឃនាយក = ព្រះសុវណ្ណប័ត្រ។

| | |
|---|---|
| ផើម (ស្ដេចស្រី) | ទ្រង់ព្រះគភ៌ |
| ផើម (ស្ដ្រីទាំងពួងជាម្នាងស្ដេច) | មានគភ៌ |
| ផឹក | ទ្រង់សោយ |

| | |
|---|---|
| ផ្កា | ព្រះបុប្ផា |
| ផ្ចិត | ព្រះនាភី |
| ផ្កាសាយ | ទ្រង់ព្រះបិនាសា |
| ផ្តិល | ព្រះស្រាពក៍ |
| ផ្ទត់ជង្គង់ | ផ្ទត់ព្រះជានុ |
| ផ្ទះ | ព្រះទីន័ងដំណាក់ |
| ផ្លិតកោង | ព្រះវីជនី |
| ផ្លិតដងង | ព្រះពាតវីជនី |
| ផ្លិតស្លឹកត្នោត | ព្រះតាលប័ត្រ |
| ផ្លិតស្លាបសត្វ | ព្រះវាលវីជនី |

---

## ៙ ព ៚

| | |
|---|---|
| ពក | ព្រះបីឡុកា |
| ពុកមាត់ | ព្រះមស្សុ |
| ពងស្វាស | ព្រះអណ្ឌៈ |
| ពាន | ព្រះពាន |
| ពានស្លា | ពានព្រះស្រី |
| ពិតាន | ព្រះពិតាន |
| ពូថៅ | ព្រះទម្រង់ផរសុ |
| ពូក | ព្រះសុខសេយ្យាស |
| ពែងផឹកទឹក | ព្រះមណិថាលកៈ |
| ពែងតែ | ព្រះបានថាលកៈ |
| ពោះ | ព្រះឧទរ |
| ពោះវៀនតូច | ព្រះអន្តគុណៈ |
| ពោះវៀនធំ | ព្រះអន្តៈ |
| ព្យាយាម | ទ្រង់ឧស្សាហ៍ |
| ព្រួញ | ព្រះទម្រង់កាំសរ |
| ព្រួយចិត្ត | ព្រួយព្រះហទ័យ (ព្រួយព្រះទ័យ, ព្រួយព្រះរាជហឫទ័យ) |
| ព្រះខាន់ | ព្រះខាន់ |

---

## ១ ភ ៚

| | |
|---|---|
| ភាជន៍ព្រះស្ងោយ | ព្រះសុវណ្ណភាជន៍ |
| ភូមិមានផ្ទះដាក់ស្វេតច្ឆត្រ | ព្រះបរមរាជវាំង |
| ភូមិមានផ្ទះឥតស្វេតច្ឆត្រ | ព្រះរាជនិវេសន៍ |
| ភូមិស្តេចទីព្រះអង្គម្ចាស់គង់ | វាំង |
| ភ្លួយ | ព្រះឧណ្ហសុភាក់ |
| ភ្នែក | ព្រះនេត្រ |
| ភ្នែកគោ | ព្រះគោប្ផកៈ |
| ភ្លេច | ទ្រង់សម្មោសា |

---

## ១ ម ៚

| | |
|---|---|
| មកុដ | ព្រះមកុដ |
| មា ឬអាពុកធំខាងអាពុក | ព្រះបិតុលា |
| មាត់ | ព្រះឱស្ឋ |
| មុខ | ព្រះភក្ត្រ |
| មុង | ព្រះសុកល់ប្រសើរ |
| មុន (រោគ) | ព្រអសា |
| ម្ជុក | ព្រះមាលា |
| មើល | ទ្រង់ទត |
| មេជើង | ព្រះអង្គុដ្ឋបាទ |
| ម្តាយជាស្តេចទីព្រះអង្គម្ចាស់ | ព្រះមាតា |
| ម្តាយជាសាស្ត្រកូនជាស្តេចទ្រង់រាជ្យ | សម្តេចព្រះរាជជននី |
| ម្តាយជាស្តេចកូនជាស្តេចទ្រង់រាជ្យ | សម្តេចព្រះវររាជជននី |
| ម្តាយមីងខាងអាពុក | ព្រះបិតុច្ឆា |
| ម្តាយមីងខាងម្តាយ | ព្រះមាតុច្ឆា |
| ម្រាមកណ្តាលដៃ | ព្រះមជ្ឈិមមង្គុលី |
| ម្រាមកូនជើង | ព្រះអនុជបាទ |
| ម្រាមកូនដៃ | ព្រះអនុជង្គុលី |
| ម្រាមជើងកណ្តាល | ព្រះមជ្ឈិមបាទ |
| ម្រាមនាងជើង | ព្រះកនិដ្ឋបាទ |

| | |
|---|---|
| ម្រាមនាងដៃ | ព្រះកនិដ្ឋង្គុលី |
| ម្រាមមេដៃ | ព្រះអង្គុដ្ឋង្គុលី |
| ម្លូបាយ | ព្រះស្រីសន្លឹក |
| ម្លូលឿង | ព្រះស្រីបណ្ណា |
| ម្សៅ | នួនព្រះភក្ត្រ |
| ម្សៅរមៀត | ព្រះហលិទ្ទចុណ្ណ |
| ម្ហូប | ព្រះឱជារស |

---

## ◎ យ

| | |
|---|---|
| យំ | ទ្រង់ព្រះកន្សែង |

---

## ◎ រ

| | |
|---|---|
| រទេះ | ព្រះទីន័ងរាជរថ |
| របស់ទ្រព្យស្តេចទ្រង់រាជ្យ | ព្រះរាជទ្រព្យ |
| របស់ទ្រព្យស្តេចទីព្រះអង្គម្ចាស់និងអ្នកអង្គម្ចាស់ | ព្រះធនទ្រព្យ |
| រង | ព្រះសថា |
| រងដាក់គ្រឿងតែ | ព្រះបានភាជន៍ |
| រងដាក់គ្រឿងបូជា | ព្រះសក្ការភាជន៍ |
| រាប់អាន | ទ្រង់ព្រះមេត្តា |
| រាស្ត្រជាម្តាយក្សត្រទីព្រះអង្គម្ចាស់ | ព្រះមាតា |
| រួមប្រវេណី | ទ្រង់ព្រះសយុម្ពរ, សយម្ពរ |
| រោងសំណាក់ | ព្រះពន្លា |
| រោងទទួលភ្ញៀវ | ព្រះរាជរោង |
| រោមក្លៀក | ព្រះលោមកច្ឆៈ |
| រោមភ្នែក | ព្រះលោមនេត្រ |
| រោមអស់ទាំងខ្លួន | ព្រះលោមា |
| រាំ | ទ្រង់ព្រះនច្ចា |

---

## ៙ ល ៚

| | |
|---|---|
| លុប ឬលាង | ទ្រង់ស្រប់ |
| លម | ព្រះថវិកា |
| លាជ | ព្រះលាជ |
| លេងល្បែងផ្សេងៗ | ទ្រង់ក្រសាល, ទ្រង់កីឡា |
| លំពែង | ព្រះទម្រង់អសុទ្ធី |
| វជម្មតា | ព្រះវ |
| វរចនា | ព្រះទីន័ងសិវិកា |
| វាយ | ទ្រង់ព្រះរាជទណ្ឌ |
| វារ | ព្រះកិលោមកៈ |
| វែករាប់បាត្រ | ស្នងព្រះហស្ត |
| វាំងនន | ព្រះសាណិយា |
| វ៉ែនតា | ស្នងព្រះនេត្រ |

---

## ៙ ស ៚

| | |
|---|---|
| សក់ | ព្រះកេសា |
| សម | ស្នងព្រះអង្គុលា |
| សលៀង | ព្រះសលៀង, ព្រះរាជយាន |
| សរសេរ | ទ្រង់លិខិត |
| សើច | ទ្រង់ព្រះសម្រួល |
| សរសៃ | ព្រះនហារូ |
| ស៊ិង | ព្រះសុពណ៌កោស |
| សង្វារ | ព្រះកេយុរា |
| សង្ស័យ | ទ្រង់វិចិកិច្ឆា |
| សន្លប់ | ទ្រង់ព្រះវិសញ្ញី |
| សន្លាក់កដៃ | ព្រះសន្ធិករ |
| សារពើបន្លែ | បន្លែព្រះស្ងោយ |
| សារពើអន្លក់ | អន្លក់ព្រះស្ងោយ |
| សាច់ | សាច់ព្រះស្ងោយ |
| សាច់ធ្មេញ (អញ្ចាញធ្មេញ) | អញ្ចាញព្រះទន្ត |

| | |
|---|---|
| សិតសក់ | ទ្រង់សិតព្រះកេសា |
| ស៊ី | ទ្រង់សោយ |
| ស្ងួត | ព្រះបច្ឆាសៈ |

-សេចក្តីដែលម្ចាស់ផែនដីតាំងទុកឲ្យមហាជនប្រព្រឹត្តតាម = ព្រះរាជបញ្ញត្តិ។
-សេចក្តីដែលម្ចាស់ផែនដីតែងដោយព្រះអង្គឯង = ព្រះរាជនិពន្ធ។
-សេចក្តីបម្រាមឬបង្គាប់ដល់ខ្ញុំរាជការឬអាណាប្រជាជន = ព្រះរាជប្រកាស។

| | |
|---|---|
| សេះគង់ | ព្រះទីន័ងអស្សតរ |
| សៃ | ព្រះកសា |
| សម្តី | ព្រះរាជតម្រាស់ |

-សំបុត្រធម្មតាដែលប្រើទៅមករកគ្នា ឬថ្វាយម្ចាស់ផែនដីនិងក្សត្រិយ៍ទាំងពួង = ចុតហ្មាយ។
-សំបុត្របុគ្គលគ្រងនគរប្រទេសរាជ = អក្សរសារ។
-សំបុត្របុគ្គលគ្រងប្រទេសឯករាជ្យ មានអំណាចដូចក្សត្រិយ៍ម្ចាស់ផែនដីប្រើចេញទៅប្រទេសក្រៅ = សុភអក្សរសារ។
-សំបុត្រមេទ័ព ឬព្រះរាជអាជ្ញាហ្លួងនូវចៅហ្វាយស្រុកក្រមការខេត្តធ្វើទៅថ្វាយម្ចាស់ផែនដី ឬសេនាបតីអំពីរាជការផ្សេងៗ = សំបុត្របក។
-សំបុត្រម្ចាស់ផែនដីចេញឲ្យដឹងទូទៅគ្រប់គ្នា = ព្រះរាជឱង្ការនូវព្រះបន្ទូលសុរសីហនាទ។
-សំបុត្រម្ចាស់ផែនដីធ្វើទៅមកដល់ម្ចាស់ផែនដីដូចគ្នា = ព្រះបរមរាជសាសន៍។
-សំបុត្រម្ចាស់ផែនដី ទ្រង់សរសេរដោយព្រះហស្តឯងពុំមែនជាផ្លូវរាជការ = ព្រះបរមរាជហត្ថលេខា។
-សំបុត្រម្ចាស់ផែនដី ទ្រង់សរសេរដោយព្រះហស្តឯងក្នុងកិច្ចរាជការ = ព្រះរាជឱង្ការលេខា។
-សំបុត្ររាជការឲ្យកាន់ទៅកោះមនុស្សឬកេណ្ឌរាស្ត្រឲ្យធ្វើការផ្សេងៗ = ហ្មាយ។
-សំបុត្រសរសេរសូមបើករបស់ផ្សេងៗ ឬធ្វើសេចក្តីទុកថ្វាយម្ចាស់ផែនដី = ដីកា។
-សំបុត្រសេនាបតីឬមេទ័ព ឬព្រះរាជអាជ្ញាហ្លួង = ទងត្រា។
-សំបុត្រព្រះរាជជននី ឬសម្តេចព្រះអគ្គមហេសី = ព្រះរាជសវនីយលេខា។
-សំបុត្រសម្តេចឧភយោរាជ, ព្រះឧបរាជប្រើជាធម្មតា = ព្រះរាជបន្ទូលលេខា។
-សំបុត្រសម្តេចឧភយោរាជ, ព្រះឧបរាជធ្វើទៅថ្វាយម្ចាស់ផែនដីដទៃក្រៅ = ព្រះបវររាជសាសន៍។
-សំបុត្រអគ្គមហាសេនាបតី ឬមេទ័ពធំ = សារត្រា។

| | |
|---|---|
| សម្បុរ | ព្រះឆវី |
| សំបោរ | ព្រះសិង្ឃានិកា |

| | |
|---|---|
| សំពត់ | ព្រះពស្ត្រ |
| សំពត់ងូតទឹក | ព្រះឧទកសាដក, សុក្ខសាដក |
| សំពត់ចាប់ទឹក | ព្រះតេមិយសាដក |
| សំពត់អង្កាញ់ | ព្រះបព្វក: |
| សម្រាលកូន | ទ្រង់ប្រសូត, ទ្រង់សម្ភព |
| សម្លក់ | ទ្រង់ឱលោកន: |
| សម្លឹង | ទ្រង់ឧលោកន: |
| សំឡេង | ព្រះសុរសៀង |
| ស្គម | ព្រះកីសោ |
| ស្ងៀម | ទ្រង់តុស្នី |
| ស្ដោះ | ទ្រង់នុដ្ឋហា |
| ស្ទាប | ទ្រង់អាមសន: |
| ស្និត (ក្រាសធ្មេញល្អិត) | ព្រះសម្អាងកេសា |
| ស្បែក | ព្រះតច: |
| ស្បែកជើង | ព្រះសុពណ៌បាទ |
| ស្បៃជ្រលក់ទឹក | ព្រះសីតសុភាក់ |
| ស្បៃដណ្ដប់ | ព្រះសុភាក់ |
| ស្ពាយធៀង | ទ្រង់ព្រះសោវត្តិកា |
| ស្មងជើង | ព្រះជង្ឃ |
| ស្មា | ព្រះអង្សា |
| ស្រឡាញ់ | ទ្រង់សព្វព្រះរាជហឫទ័យ |
| ស្រា | ព្រះចណ្ឌរស |
| ស្រេក | ទ្រង់បិបាសា |
| ស្រែង | ព្រះកិលាស: |
| ស្រោមជើង | ព្រះសុពណ៌កោសបាទ |
| ស្លាក្រក | ព្រះស្រីឧណ្ឌក៏ |
| ស្លាជីគ្រប (ស្លាជីប) | ព្រះបិធាន |
| ស្លាខ្ចី | ព្រះស្រីហរិត |
| ស្លាតម្កល | ព្រះស្រីតម្ពូល |
| ស្លាបុក | ព្រះស្រីចុណ្ណ: |
| ស្លាស្លឹង | ព្រះស្រីសុក្ខ |
| ស្លាបប៉ាកកា | ព្រះគរុកំ |

| | |
|---|---|
| ស្លាបប្រចៀវ | ព្រះវង្សកុបាត |
| ស្លាបព្រា | ស្នងព្រះអង្គុលី |
| ស្លាប់ (លោកសង្ឃ) | អនិច្ចកម្ម |
| ស្លាប់ (ស្ដេចទ្រង់រាជ្យ) | សោយព្រះទិវង្គត |
| ស្លាប់ (ស្ដេចទីព្រះអង្គម្ចាស់) | សុគត |
| ស្លាប់ (ស្ដេចទីអ្នកអង្គម្ចាស់) | ក្ស័យព្រះជន្ម |
| ស្លាប់ (អគ្គមហេសី) | សោយព្រះវិលាល័យ |
| ស្លេស្ម | ព្រះសេម្ហៈ |
| ស្វេតច្ឆត្រ | ស្វេតច្ឆត្រ |
| ស្អូច | ព្រះកិបិលកា |

---

## ៙ ហ ៚

| | |
|---|---|
| ហិត | ទ្រង់ឃាយី |
| ហឺប | ព្រះមញ្ជូសា |
| ហឺត | ព្រះសាសរោគ |
| ហែមស្លាព្រះពរ | ស្រោពក៏ព្រះស្រី |

---

## ៙ អ ៚

-អក្សរក្សត្រិយ៍ខត្តិយត្រកូលផងទាំងពួង = ឡាយព្រះហស្តលេខា។
-អក្សរម្ចាស់ផែនដីទ្រង់សរសេរ ដោយព្រះហស្តឯងទុកជាចំណាំនៃព្រះអង្គ = ព្រះរាជហត្ថលេខា។

| | |
|---|---|
| អង្គុយ | ទ្រង់គង់, ទ្រង់និសីទនាការ |
| អង្កែល | ទ្រង់បរាមាសៈ |
| អណ្ដាត | ព្រះជីវ្ហា |
| អផ្សង់ | ព្រះសិទ្ធលិង្គរោគ |
| អផ្ទាញ | ព្រះរោគសិទ្ធលិង្គ |
| អំបែងក្បាល | ព្រះមត្ថកៈ |
| អាណិត | ទ្រង់ព្រះករុណា |
| អាចម៍ | ព្រះករីសៈ |
| អាចម៍ប្រមុះ | ព្រះឃានមលៈ |

| | |
|---|---|
| អាចម៍រុយ (ប្រជ្រុយ) | ព្រះកាឡក: |
| អាជ្ញា | ព្រះរាជអាជ្ញា |
| អាវ | ព្រះភូសា |
| អុតធំ | ព្រះគណ្ឋរោគ |
| អុតស្វាយ | ព្រះគណ្ឋយា |
| ឧស្សាហ៍ | ព្រះឧស្សាហ៍ |
| ឪពុកធំ ឬមាខាងម្ដាយ | ព្រះមាតុលា |
| ឱប | ទ្រង់អាលិង្គន: |
| អំពល់ចិត្ត | ទ្រង់អនីយ: |

---

ព្រះបាទសម្ដេចព្រះហរិរក្សរាមា ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់ព្រះចិន្ដាយល់ថា រាជសព្ទបុរាណដែលធ្វើទុកមក ថាបើក្សត្រជាស្ដេចទ្រង់រាជ្យហើយយកស្ដេចស្រ្ដីឯណាជាមហេសី បើមាតាបិតាបានរៀបអាពាហ៍ពិពាហ៍ត្រូវហៅដូច្នេះ បើយកខ្លួនឯងត្រូវហៅដូច្នោះ បើយកស្រ្ដីដែលមិនមែនជាស្ដេច ក៏សឹងឲ្យហៅថាដូច្នេះដូច្នោះ សេចក្ដីទាំងអម្បាលនេះ ទ្រង់ព្រះតម្រិះយល់ថា នឹងសន្មតហៅពុំបាន លុះតែម្ចាស់ផែនដីទ្រង់តាំងនាមហើយមានព្រះរាជពិធីឲ្យធ្វើដូច្នេះដូច្នោះទើបហៅបាន ទើបទ្រង់មានព្រះរាជបញ្ញត្តិ ទុកជា បែបបទបើនឹងតាំងជាទីអ្វីក្ដី ត្រូវឲ្យមានសុវណ្ណប័ត្រ ហើយឲ្យមានពិធីព្រាហ្មណ៍ធ្វើផ្សេងៗ ដើម្បីជាច្បាប់សណ្ដាប់ព្រះរាជប្រវេណីតទៅឲ្យដឹងដូច្នេះ។

**ប្រការ១** - បើម្ចាស់ផែនដីយកខត្តិយកញ្ញាឯណាជាបាទបរិចារិកា មានវិធីព្រាហ្មណ៍ទឹកក្លស់ទឹកស័ង្ខ លើព្រះរាជអាសន៍បុស្បុក្សរួមជាមួយនឹងម្ចាស់ផែនដី វីខត្តិយកញ្ញានោះហៅថា **សម្ដេចព្រះអគ្គមហេសី** ឬ **សម្ដេចព្រះអារអគ្គមហេសី** តាមសុវណ្ណប័ត្រ បើមានពិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខ តែពុំបានរួមអាសន៍នឹងម្ចាស់ផែនដីទេហើយបានទ្រង់ព្រះរាជទាន ទឹកស័ង្ខដោយព្រះហស្ដឯងអង្គយកន្លែងទាបជាងម្ចាស់ផែនដី ហៅថា **សម្ដេចព្រះអគ្គរាជទេពី** ឯខត្តិយកញ្ញាដូចមានព្រះនាមមកនេះ បើមានព្រះរាជបុត្រនឹងម្ចាស់ផែនដីបើជាក្សត្រហៅថា **សម្ដេចព្រះរាជឱរស**, **សម្ដេចបរមរាជឱរស**, ឬ **សម្ដេចព្រះបរមរាជបុត្រា** ឬ **សម្ដេចព្រះអយ្យបុត្រ** ក៏បាន បើជាក្សត្រិយ៍ហៅថា **សម្ដេចព្រះរាជធីតា** ព្រះនាមទាំងអម្បាលនេះស្រេចហើយតែទ្រង់តាំង។

**ប្រការ២** - ខត្តិយកញ្ញាឯណាដែលម្ចាស់ផែនដីយកជាបាទបរិចារិកា តែ ពុំបានទ្រង់ព្រះរាជទានព្រះបរមរាជានុញ្ញាត ឲ្យមានពិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខ គ្រាន់តែ

ទ្រង់ទទួលយកស័ង្ខអំពីដៃព្រាហ្មណ៍មកព្រះរាជទាន រីខត្តិយកញ្ញានោះហៅថា **ព្រះអគ្គជាយា** បើ មានព្រះរាជបុត្រនឹងម្ចាស់ផែនដី ទោះបីជាក្សត្រាក្ដី ក្សត្រិយ៍ក្ដី ហៅថា **សម្ដេចព្រះរាជបុត្រា-បុត្រី** តែយសថយជាងក្សត្រទីសម្ដេចក្នុងប្រការ១ បើថាពុំមានសុវណ្ណប័ត្រតាំងជាព្រះអគ្គជាយាទេ ត្រូវហៅតាមនាមដើម បើមានព្រះរាជបុត្រហៅថា **ព្រះរាជបុត្រាបុត្រី** ព្រះអង្គម្ចាស់នេះនោះ។

**ប្រការ៣** - បើម្ចាស់ផែនដីទ្រង់យកស្ត្រីទាំងពួង ក្រៅចាកអំពីក្សត្រខត្តិយកញ្ញាមកជាបាទបរិចារិកា ហើយបានទ្រង់ព្រះមេត្ដាប្រោសព្រះរាជទានទឹកស័ង្ខដោយព្រះហស្ដឯង រីស្ត្រីនោះហៅថា **ចៅចម** ឯចៅចមមាន **៦ ជាន់** ដូចមាននាមដូច្នេះ ៖

ទី១ - ព្រះបិយា ងារជាព្រះបរម
ទី២ - ព្រះស្នំ ងារជាព្រះម្នាង
ទី៣ - ព្រះស្រីង្គារ ងារជាព្រះម៉ែនាង
ទី៤ - ព្រះក្រុមការ ងារជាព្រះនាង
ទី៥ - ព្រះស្រីការ ងារជាអ្នកម្នាង
ទី៦ - ព្រះកំណាន់ ងារជាអ្នកនាង

រួមទាំងអស់ហៅថា **ចៅចម** សុទ្ធសឹងមានព្រះរាជឱង្ការតាំងនាម ឯស្ត្រីក្រៅអំពីនេះហៅថា **អស់ទាំងអ្នក** រីស្ត្រីទាំងអម្បាលនេះ បើមានព្រះរាជបុត្រនឹងម្ចាស់ផែនដីហៅថា **ព្រះអង្គម្ចាស់** ទាំងអស់ដូចគ្នា បើចេញចុតហ្មាយឡាយព្រះហស្ដឲ្យថា **ព្រះរាជបុត្រា-បុត្រី** ព្រះអង្គម្ចាស់នេះ-នោះតាមព្រះនាម តែ មានយសថយជាងក្សត្រទីសម្ដេចក្នុងប្រការ២ ត្រូវអង្គុយក្រោយ ឯក្សត្រក្នុងប្រការ៣ បើនឹងស្រដីនឹងក្សត្រជាទីសម្ដេចព្រះរាជឱរស-ធីតា ត្រូវនិយាយ **ទូលបង្គំជាខ្ញុំៗម្ចាស់** ឆ្លើយថា **ព្រះករុណាពិសេស, មែម្ចាស់**។

**ប្រការ៤** - ក្សត្រឯណា ជា សម្ដេចព្រះឧភយោរាជក្ដី ព្រះ មហាឧបរាជក្ដី យកខត្តិយកញ្ញាឯណាជាបាទបរិចារិកា ហើយមានពិធីព្រាហ្មណ៍ថ្វាយទឹកក្លស់ទឹកស័ង្ខលើរាជអាសន៍រួមជាមួយនឹងស្វាមី រីខត្តិយកញ្ញានោះមានព្រះនាមហៅថា **សម្ដេចព្រះមហេសី** បើពុំបានរួមរាជអាសន៍នឹងព្រះស្វាមីទេ គឺអង្គុយទីដទៃ ហើយទទួលទឹកស័ង្ខហៅថា **ព្រះរាជទេពី** បើមានព្រះបិយបុត្រក្សត្រាក្ដីក្សត្រិយ៍ក្ដី នឹងថ្វាយព្រះនាមជា**សម្ដេច** ក៏បាន តែត្រូវយកសេចក្ដីក្រាបបង្គំទូលអម្ចាស់ផែនដីសូមព្រះរាជទានព្រះសុវណ្ណប័ត្រ បើទ្រង់ព្រះមេត្ដាប្រោសព្រះរាជទានព្រះបរមរាជានុញ្ញាតទើបតាំងបាន នឹងតាំងដោយអំពើព្រះរាជហឫទ័យឯងពុំបាន បើក្សត្រទីឧភយោរាជឬមហាឧបរាជ យកស្ត្រីពុំមែនជាក្សត្រមកធ្វើជាបាទបរិចារិកា ទ្រង់ព្រះរាជទានព្រះបរមរាជានុញ្ញាត ឲ្យតាំងដោយព្រះអង្គឯងបាន តាំងអំពីទីព្រះទីក្រុមការចុះមក បើមានព្រះឱរស-ធីតា ហៅថា **ព្រះអង្គម្ចាស់** ទាំងអស់ដូច

ព្រះរាជបុត្រម្ចាស់ផែនដី តែ យសថយជាងព្រះរាជបុត្រម្ចាស់ផែនដី ត្រូវអង្គុយក្រោយព្រះរាជបុត្រម្ចាស់ផែនដី ឯព្រះរាជបុត្រក្សត្រ ទីព្រះមហាឧបរាជត្រូវអង្គុយក្រោយព្រះឱរស-ធីតាក្សត្រទីព្រះឧភយោរាជ ដ្បិតយសថយជាងក្សត្រឧភយោរាជ ឯព្រះអង្គម្ចាស់ជាព្រះឱរស-ធីតាក្សត្រទាំងពីរព្រះអង្គ ដូចមានព្រះនាមមកនេះ បើនឹងចេញចុតហ្មាយឡាយព្រះហស្ត ដាក់ថា **ចុតហ្មាយព្រះរាជបុត្រា** ឬ**ព្រះរាជបុត្រី**ព្រះអង្គម្ចាស់នេះ ដូចព្រះរាជបុត្រក្សត្រទ្រង់រាជ្យ ជាអម្ចាស់ផែនដីពុំបាន។

**ប្រការ៥** - បើក្សត្រទីសម្តេចជាព្រះរាជបុត្រក្សត្រទ្រង់រាជ្យក្តី ឬព្រះរាជបុត្រក្សត្រឧភយោរាជ, ឧបរាជក្តី យកស្តេចក្សត្រិយ៍ខត្តិយកញ្ញាឯណាទីព្រះអង្គម្ចាស់ជាបាទបរិចារិកា ហៅថា **ព្រះទេពី** បើមានបិយបុត្រក្សត្រា ហៅថា **ព្រះឱរស** បើជាក្សត្រិយ៍ហៅថា **ព្រះធីតា ព្រះអង្គម្ចាស់**នេះ-នោះ ដូចព្រះរាជបុត្រក្សត្រទីព្រះឧភយោរាជ, ព្រះមហាឧបរាជ ឲ្យយសថយជាងក្សត្រព្រះឱរស-ធីតាក្សត្រទាំងពីរ គឺ**សម្តេចព្រះឧភយោរាជ ព្រះមហាឧបរាជ** ដូចចេញព្រះនាមមកនេះ តែត្រូវអង្គុយបន្ទាប់ ក្សត្រជាព្រះឱរស-ធីតាព្រះមហាឧបរាជ បើក្សត្រទីសម្តេចយកខត្តិយកញ្ញាឯណាទីអ្នកអង្គម្ចាស់ ជា បាទបរិចារិកា ហៅថា **ព្រះជាយា** បើមានព្រះឱរស-ធីតា ហៅថា **អ្នកអង្គម្ចាស់** បើយកស្រ្តីក្រៅចាកខត្តិយកញ្ញាគឺអ្នករាជវង្សក្តី ឯបុត្រសេនាបតីចតុស្តម្ភក្តី ឬបុត្រមន្ត្រីនូវបុត្រអាណាប្រជាជនទាំងពួង មកធ្វើជាបាទបរិចារិកា ហៅថា **អ្នកម្នាង** បើមានព្រះឱរស-ធីតា ហៅថា **អ្នកអង្គម្ចាស់** ដូចគ្នា។

**ប្រការ៦** - បើក្សត្រទីព្រះអង្គម្ចាស់ យកខត្តិយកញ្ញាឯណាទីព្រះអង្គម្ចាស់ដូចគ្នាជាបាទបរិចារិកា ហៅថា **ព្រះជាយា** បើ មានព្រះបិយបុត្រជាក្សត្រា ហៅថា **ព្រះឱរស** ជាក្សត្រិយ៍ហៅថា **ព្រះធីតា** ទីព្រះអង្គម្ចាស់ដូចព្រះវរបិតា-មាតា ដោយហេតុមានជាតិស្មើគ្នា បើយកស្រ្តីទីអ្នកអង្គម្ចាស់ជាបាទបរិចារិកាហៅថា **ជាយា** បើមានព្រះបិយបុត្រហៅថា**ព្រះឱរស-ធីតា** តែជាទីអ្នកអង្គម្ចាស់ ព្រោះព្រះមាតាមានជាតិពុំស្មើនឹងព្រះបិតា បើយកស្រ្តីជាអ្នករាជវង្សក្តី ព្រះវង្សក្តី ឬបុត្រសេនាបតីនូវបុត្រប្រជាជនទាំងពួងជាបាទបរិចារិកាហៅថា **អ្នកម្នាង** បើមានបិយបុត្រឲ្យហៅថា **ព្រះឱរស-ធីតា** ដូចគ្នា តែជាទីអ្នកអង្គម្ចាស់។

**ប្រការ៧** - បើអ្នកអង្គម្ចាស់យកក្សត្រិយ៍ទីអ្នកអង្គម្ចាស់ដូចគ្នា ជា បាទបរិចារិកា ហៅថា **ជាយា** បើ មានបិយបុត្រហៅថា **ព្រះឱរស-ធីតា** ទីអ្នកអង្គម្ចាស់ដូចព្រះបិតា-មាតា ដ្បិតមានជាតិស្មើគ្នាទាំងពីរ បើយកស្រ្តីក្រៅចាកទីអ្នកអង្គម្ចាស់ដូចគ្នាជាបាទបរិចារិកា ហៅថា **សម្រាប់** បើមានបិយបុត្រហៅថា **ឱរស, ធីតា** ជាទីអ្នករាជវង្ស ឯទីអ្នករាជវង្សនេះពុំត្រូវប្រើពាក្យរាជសព្ទថាសោយថាស្រង់ឡើយ ត្រូវឲ្យនិយាយតាមធម្មតា។

**ប្រការ៨** - បើអ្នករាជវង្ស និងអ្នករាជវង្សយកគ្នាជាស្វាមីភរិយា ហើយមានបុត្រឲ្យ

ហៅថា បុត្រប្រុស បុត្រស្រ្តី ជាទីអ្នករាជវង្សដូចមាតាបិតា ដ្បិតមានជាតិស្មើគ្នា បើអ្នករាជវង្សទៅយកស្រ្តីទីព្រះវង្សក្តី ឬស្រ្តីមានជាតិទាបជាងក្តីជាភរិយា ហើយមានបុត្រ ឲ្យហៅថា **ព្រះវង្ស**។

**ប្រការ៩** - បើព្រះវង្សនិងព្រះវង្សយកគ្នាជាស្វាមីភរិយា ហើយមានបុត្រឲ្យហៅថា **ព្រះវង្ស** ដ្បិតមាតាបិតាមានជាតិស្មើគ្នា បើជាព្រះវង្សទៅយកភរិយាក្រៅចាកព្រះវង្ស បើមានបុត្រត្រូវដាច់ក្រសែព្រះវង្សនឹងហៅថាព្រះវង្សពុំបាន ដ្បិតមាតាបិតាមានជាតិពុំស្មើគ្នា៕ ៚

**៙ ចប់ ៚**

បើលោកអ្នកចង់បានសៀវភៅខ្មែរផ្សេងៗទៀតសូមចូលទៅ :
ប្លុកអាក្បាលធំ www.akbalthom.blogspot.com
សូមអរគុណ!